# ជំនួយហិរញ្ញវត្ថុនៅ MultiCare

ប្រព័ន្ធសុខាភិបាល MultiCare បានប្ដេជ្ញាចិត្តក្នុងការបម្រើអ្នកជំងឺទាំងអស់រួមទាំងអ្នកដែលមិនមានការធានារ៉ាប់រងសុខភាព និងអ្នកដែលមិនអាចបង់ថ្លៃទាំងអស់ ឬមួយផ្នែកនៃសេវាថែទាំដែលចាំបាច់ដែលពួកគេទទួលបាន។ យើងប្ដេជ្ញាចិត្តព្យាបាលអ្នកជំងឺទាំងអស់ដោយមេត្តាធម៌។ យើងប្ដេជ្ញារក្សាគោលនយោបាយស្ដីពីជំនួយហិរញ្ញវត្ថុដែលស្របតាមបេសកកម្ម និងគុណតម្លៃរបស់យើង ហើយដែលគិតគូរពីសមត្ថភាពរបស់បុគ្គលម្នាក់ៗក្នុងការបង់ថ្លៃសេវាថែទាំសុខភាពដែលចាំបាច់។ ដើម្បីស្វែងយល់បន្ថែមអំពីរបៀបដែលក្រុមជំនួយផ្នែកហិរញ្ញវត្ថុរបស់យើងអាចជួយអ្នកជាមួយកម្មវិធីជំនួយហិរញ្ញវត្ថុរបស់យើង **សូមចូលទៅកាន់គេហទំព័រ www.multicare.org/financial-assistance ឬហៅទូរស័ព្ទទៅកាន់លេខ៖ 800-919-1936**

**គោលនយោបាយស្ដីពីជំនួយហិរញ្ញវត្ថុ**

គោលនយោបាយស្ដីពីជំនួយហិរញ្ញវត្ថុពេញលេញអាចរកបានតាមអនឡាញ ឬតាមទូរស័ព្ទ។ សូមចូលមើលគេហទំព័រ www.multicare.org/financial-assistance។

**ព័ត៌មានខាងក្រោមនេះសង្ខេបអំពីកម្មវិធីជំនួយហិរញ្ញវត្ថុរបស់យើង។**

MultiCare ប្រើប្រាស់គោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធ ដើម្បីជួយកំណត់ថាតើកម្មវិធីជំនួយហិរញ្ញវត្ថុណាមួយដែលស័ក្តិសមនឹងតម្រូវការរបស់អ្នក។

**ប្រាក់ចំណូលមានរហូតដល់ 300% នៃគោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធ**

បន្ទាប់ពីការវាយតម្លៃហិរញ្ញវត្ថុនៃប្រាក់ចំណូលរបស់អ្នកជំងឺត្រូវបានបញ្ចប់ វិក្កយបត្ររបស់អ្នកជំងឺនឹងត្រូវបានកាត់បន្ថយត្រឹម 100% ក្នុងករណីប្រាក់ចំណូលរបស់ពួកគេស្ថិតនៅក្រោម ឬតិចជាង 300% នៃគោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធ។

**ប្រាក់ចំណូលគឺ 301 – 500% នៃគោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធ**

ន្ទាប់ពីការវាយតម្លៃហិរញ្ញវត្ថុនៃប្រាក់ចំណូល និងទ្រព្យសម្បត្តិរបស់អ្នកជំងឺត្រូវបានបញ្ចប់ វិក្កយបត្ររបស់អ្នកជំងឺនឹងត្រូវបានកាត់ន្ថយក្នុងករណីកម្រិតប្រាក់ចំណូលរបស់ពួកគេមានចាប់ពី 301% ដល់ 500% នៃគោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធ។

## គោលការណ៍ណែនាំស្ដីពីភាពក្រីក្ររបស់សហព័ន្ធឆ្នាំ 2018

| កម្រិតប្រាក់ចំណូល៖ | | | | | | |
|---|---|---|---|---|---|---|
| ទំហំគ្រួសារ | ប្រាក់ចំណូលដុលប្រចាំឆ្នាំ | 300% | 350% | 400% | 450% | 500% |
| 1 | $12,140 | $36,420 | $42,490 | $48,560 | $54,630 | $60,700 |
| 2 | $16,460 | $49,380 | $57,610 | $65,840 | $74,070 | $82,300 |
| 3 | $20,780 | $62,340 | $72,730 | $83,120 | $93,510 | $103,900 |
| 4 | $25,100 | $75,300 | $87,850 | $100,400 | $112,950 | $125,500 |
| 5 | $29,420 | $88,260 | $102,970 | $117,680 | $132,390 | $147,100 |
| 6 | $33,740 | $101,220 | $118,090 | $134,960 | $151,830 | $168,700 |
| 7 | $38,060 | $114,180 | $133,210 | $152,240 | $171,270 | $190,300 |
| 8 | $42,380 | $127,140 | $148,330 | $169,520 | $190,710 | $211,900 |
| 9 | $46,700 | $140,100 | $163,450 | $186,800 | $210,150 | $233,500 |
| 10 | $51,020 | $153,060 | $178,570 | $204,080 | $229,590 | $255,100 |
| បន្ថែមសម្រាប់មនុស្សម្នាក់ៗ | $4,320 | | | | | |

| ការបញ្ចុះតម្លៃរបស់ប្រព័ន្ធសុខាភិបាល MultiCare | | | | | |
|---|---|---|---|---|---|
| កម្រិតក្រីក្ររហូតដល់ | 300% | 350% | 400% | 450% | 500% |
| ការបញ្ចុះតម្លៃសប្បុរសធម៌ | 100% | 95% | 90% | 80% | 70% |
| ការទទួលខុសត្រូវរបស់អ្នកជំងឺ | 0% | 5% | 10% | 20% | 30% |

MultiCare

87-0368-1CA (9/18)